Theology on the Web.org.uk

Making Biblical Scholarship Accessible

This document was supplied for free educational purposes. Unless it is in the public domain, it may not be sold for profit or hosted on a webserver without the permission of the copyright holder.

If you find it of help to you and would like to support the ministry of Theology on the Web, please consider using the links below:

Buy me a coffee https://www.buymeacoffee.com/theology

PATREON https://patreon.com/theologyontheweb

PayPal https://paypal.me/robbradshaw

---

A table of contents for *Honeycomb* can be found here:

https://biblicalstudies.org.uk/articles_honeycomb.php

HONEYCOMB 4/1 (January 2003): 51–59



# Balancing Praying with Doing

*Russell H. BOWERS, Jr.*

Christians sometimes say, "If only we would pray, God would change our world." "Prayer meeting is the most important meeting of the week—the 'Hour of Power'." "Satan doesn't care what else we do, as long as we don't pray." All this implies that our talking to God outweighs God's talking to us (as we scrutinize the scriptures). It throws back into God's lap responsibilities he has assigned us. And it leads to a flurry of prayer and fasting vigils, seminars, and conferences.

Certainly prayer *is* essential. God *does* meet with us when we call on him. His Spirit aids our praying, unmasks our sins, breaks our pride, and draws us to Christ. God does answer prayer, and "is able to do immeasurably more than all we ask or imagine." But some people speak as if prayer were the whole of our responsibility—as if all we need do is pray and wait. That is wrong. Though prayer is *a* key to God's blessing, it is not the *only* key. Another is informed obedience.

Some people balk at that. Obedience sounds so pedestrian next to prayer. Isn't obedience a *human* work? Would not our efforts detract from the supernaturalness of revival? Would not God's glory

be dimmed if human contributions played a part? Are we talking synergism here?

So we bristle with Naaman and mutter, "I thought that he would surely come out to me and stand and call on the name of Yahweh his God, wave his hand over the spot and cure me. . . ." Naaman nearly forfeited his cure because he wanted to wait and watch God work, rather than participate by plunging into the Jordan. How we crave the passive (on our part) and the spectacular (on God's)!

But although there were times when God's people were to watch and do nothing (ask Jehoshaphat), there were others when God said, "Stop praying and start doing." This is the message we need today.

**Times to Stop Praying and Start Acting**

Joshua was leading Israel into Canaan. The nation had defeated Jericho, but lost at Ai. Israel's panicked leaders fell prostrate and prayed. Nothing wrong with that, but what did God say? "Stand up! What are you doing down on your face?" In brief God said, "*Stop praying*. Start acting. You have disobeyed. Correct the problem." Had Joshua insisted on continuing to *pray* when God said to *do*, Israel would have lost again. Do we ever substitute prayer for our nation or churches when there is obvious practical work that *we* should do?

Judah in Isaiah's day longed for revival. The nation prayed for it, but nothing happened. They wondered why.

> . . . [D]ay after day they seek me out;
>   they seem eager to know my ways,
> as if they were a nation that does what is right
>   and has not forsaken the commands of its God.
> They ask me for just decisions
>   and seem eager for God to come near them.
> 'Why have we fasted,' they say,
>   'and you have not seen it?
> Why have we humbled ourselves,
>   and you have not noticed?'

They prayed, but no revival followed. When they asked why, God told Isaiah to denounce their sin. If they would rise from their knees and obey him in their everyday relationships and responsibilities, God would answer. They needed to loose the chains of injustice, share their food with the hungry, do away with malicious talk, etc. These may not sound as "spiritual" as prayer vigils and fasts. They have to do with human actions and human relationships, not spectacular divine displays. But these, and not prayer, were the keys which would unlock revival:

> Then your light will break forth like the dawn,
> and your healing will quickly appear. . . .
> You will be like a well-watered garden,
> like a spring whose waters never fail.

Blessing for Judah would follow obedience, not more prayer and fasting.

We resist such counsel at our own peril. "Hear the word of Yahweh, all you people of Judah who come through these gates to worship Yahweh. This is what Yahweh Almighty, the God of Israel, says: *Reform your ways and your actions*, and I will let you live in this place." (Notice that God does not say, "Start a 24-hour prayer vigil," or "Go on a prolonged fast." He doesn't say, "Start praying to me," but "Start doing right to people.") "Do not trust in deceptive words and say, 'This is the temple of Yahweh, the temple of Yahweh, the temple of Yahweh!' If you really change *your ways and your actions* and deal with each other justly, . . . then I will let you live in this place. . . . But look, you are trusting in deceptive words that are worthless." These deceptive words suggested that Judah need not obey, but should instead continue to "worship." Unfortunately Judah ignored Jeremiah, and God sent Nebuchadnezzar to end their empty temple prayer meetings.

## Attempting to Give Back to God The Work He Gave Us

Does the same thing happen today? Do we ever pray when God tells us to act? Has any church ever tried to return to God the

responsibilities he has assigned to us? This, I suppose, would be the ultimate in "upward delegation."

For example, God commands us to evangelize. We invert that command and pray that *he* would do it—that he would somehow "open the hearts" of our neighbors while we say nothing to them. Perhaps we erect a church sign to inform passing sinners when we meet, but then fail to think up ways to creatively introduce them to Christ. There is nothing wrong with pleading for God's aid in our evangelism, but only if we plan to participate in the process. Or we "fulfill" our responsibilities to the sick and elderly by praying that God would comfort them, but ourselves neither call nor offer a meal. We pray that God would correct our nation's moral problems, yet write no protesting letters and watch the same videos as everybody else. We are commissioned to reach the world with the gospel, yet some churches tend to keep to themselves. God urges us to value our families and people and we chase things. Yet we pray for revival. What's wrong with this picture?

## Why Some People Prefer "Praying"

Why do we prefer prayer to action? One reason may be laziness. It is simply easier to open our mouths in windy prayer than to expend our lives in costly obedience. Actually building a house for a poor person is sweatier than praying that God house the needy. Finding out how best we can serve our neighbors, and then doing things for them that will open them to the gospel, exhausts us more profoundly than merely requesting that God speak to them, and then blindly plowing ahead with our Same Old Thing. Work is messier, too. When we struggle with people we make mistakes. We do things wrong, blunder up blind alleys, lose our patience, and drop the ball. We find ourselves needing to apologize and start over. We face criticism and ridicule. How much less traumatic and error-prone to instead intone orthodox prayers from our church buildings. We prefer prayer to obedience because of the *toil* of obedience.

A warning—good praying is also strenuous. Epaphras *wrestled* in prayer, and thus worked hard for the Asian churches. But while Epaphras worked hard at prayer he was surrounded by

those who worked hard at the *work*. The early church did not deceive itself into thinking prayer alone was the answer.

A second reason we prefer prayer to action is selfishness. Selfishness means I pursue my perceived best interest. Christianity, the church, people, and ultimately God, all exist to fulfill and make me comfortable. And while, in Christian charity, I am willing to pray that *God* bless others, *I* cannot reasonably be expected to sacrifice myself to help bring that blessing about. Prayer is cheaper; obedience costs too much.

Third, perhaps an inadequate loathing of sin blunts our urgency to obey God. We reduce sin to a theological concept—the reason why Christ came—and quote verses on its nature and consequences. Sin becomes only an abstract idea, not a concrete choice and terrible habit. But to God sin is not a tome on our theological shelves. It is a stench, and stirs his wrath and judgment. And while through the blood of Christ God forgives sin, we must learn to loath it, fear it, and run the other way. The church cannot dawdle in iniquity—either wrong things we do or right things we don't—and expect God to bless simply because we ask him to. If revival is what we want, certainly we will plead for it. But we will also in fear and faith obey the God who grants it.

A fourth reason we prefer prayer to action is that some people don't understand how important are the things we do. They think that if *humans* contribute to a ministry, it will detract from the glory of *God* in the fruit it bears. But that is not true. Rather than "Get out of the way and let God work," we must learn to "Get on board and do what God is doing." Paul did not think it was either God or us—he meant it when he called his team "God's fellow workers."

## God Uses People

Certainly God is not limited to using humans when he wants to do something. We served as neither consultants nor engineers when he made the world. God is sovereign; he is free to work when and how he chooses. But frequently and meaningfully God nevertheless does use people to accomplish his will.

Christians understand that the Bible is the word of God. The whole was breathed out by God. And while that is true, there is not a word of it that did not pass through the mind and flow from the pen of a man as well. *Paul* (not God) was the one who was on the verge of wishing himself cursed and cut off from Christ; *Jude* the person who was eager to write about salvation but felt compelled to address a different matter; *Luke* the individual who thought it good to write a gospel account, and so researched and composed it. The Bible is one hundred percent the word of God, but it is simultaneously one hundred percent the word of man. When God determined that humanity should have a written record of his will, he did not supernaturally float it down from the skies. Human beings struggled . . . and thought . . . and wrote . . . and sometimes rewrote. Through the centuries *God* has preserved that word as *people* copied, hid, carried, and translated it. Though he does not need to, God often accomplishes his work through people.

The humanity of Jesus is as essential to evangelical Christology as is his deity. Jesus was a man. We must remember that "the resurrection of the dead comes also through a *man* . . . there is one God and one mediator between God and men, the *man* Christ Jesus . . . he had to be made *like his brothers in every way*, in order that he might become a merciful and faithful high priest in service to God, and that he might make atonement for the sins of the people. . . ." God's salvation was not diluted by his using the *man* Jesus of Nazareth to accomplish it. On the contrary, salvation would have been impossible had that man not participated. Like the written word, the incarnate word is one hundred percent divine and one hundred percent human. Being human Christ could say, "I have set you an example that you should do as I have done for you." Eternal salvation is the work of God. But because Jesus is the savior it is also the work of a man—one who was like us in every way. God's glory is not diminished when he uses people—and their obedience and sacrifices—to accomplish his plan.

## Who Builds the Church?

By what means does the church grow today? Jesus said, "*I* will build my church." The book of Acts begins: "In my former book, Theolophilus, I wrote about all that *Jesus* began to do and to teach. . . ." This implies that Acts records what Jesus *continued* to do and to teach. But how does Jesus build his church? How does he continue to do and teach? Through people. Acts records some of their sailings . . . struggles . . . sermons . . . and sufferings. Paul told the Colossians, "I fill up in my flesh what is still lacking in regard to Christ's afflictions for the sake of his body, which is the church. . . . I want you to know how much I am struggling for you. . . ." Acts says that *Christ* was building the Colossian church. Colossians says that *Paul* was building the Colossian church. How do these two fit together? Christ was building the church through Paul. God does his work through people. And Christ builds his church today as *people* obey him—choose not to get out of his way, but rather get on board and do what he is doing. No church is built without the evangelism, teaching, giving, serving, and labor of people . . . as they are motivated and empowered by the spirit of God. The church grows and builds itself up in love *as each part does its work*, not as each part sits and waits for God to do his work. It is simultaneously the work of God and people.

The same with revival. Sure we need to pray for it. But we also need to work for it. Our work does not detract from God's work, or diminish his glory when the answer comes. God often does his work *through people*. So we need more calls for the church to quit the monastery and obey God in the marketplace. When we are busy practicing daily righteousness

> Then [our] light will break forth like the dawn,
> and [our] healing will quickly appear. . . .
> [We] will be like a well-watered garden,
> like a spring whose waters never fail.

Pentecost is not going to be repeated; there is no need to pray for that to happen. The church already stands "clothed with power from on high." We need more calls to take the tasks we have been given and fulfill them in the strength God provides.

## What Does God Want?

Christianity is not that complicated. Does the Almighty crave our self-denying ritual? The prophet ponders that question:

With what shall I come before Yahweh
and bow down before the exalted God?
Shall I come before him with burnt offerings,
with calves a year old?
Will Yahweh be pleased with thousands of rams,
with ten thousand rivers of oil?
Shall I offer my firstborn for my transgression,
the fruit of my body for the sin of my soul?
He has showed you, O man, what is good.
And what does Yahweh require of you?
To act justly and to love mercy
and to walk humbly with your God.

Micah's conclusion is simple. God does not seek our prolonged prayers or extended fasts. He is not as impressed with showy display as he is with daily obedience. Similarly, the answer to the psalmist's question, "Yahweh, who may dwell in your sanctuary?" doesn't mention religious ritual, but instead discusses practical, daily righteousness. When people asked John the Baptist, "What should we do?" he answered mundanely: "Donate your excess, act honestly, be content." Nothing spectacular or "religious" here. Yet God would bless if people obeyed.

How often do we say, "I'll pray for you," when what we need to say is, "Let me help you"? Prayer is not the end of our responsibility but the beginning: it opens the door for God to direct and strengthen us for our tasks. However one may assess her theology, Mother Theresa did more through her deeds to make Christianity and Christ respectable in non-Christian India than do the genuflections of thousands who may think more biblically but who do nothing. "Dear children, let us not love"—or seek revival, or attempt to win the lost—"with words or tongue but with actions and in truth."

Doubtless our nation needs God's hand upon us. Certainly we should pray for that. But no less surely we need to be doing what God has commanded. We need to rise from our knees and go with

our feet, help with our hands, speak with our tongues, and embrace with our arms. Prayer is *a* key to revival, but so is obedience. God answers, but he often answers through people. Perhaps his answer will include us. May we not be guilty of sitting and sighing, "I wish *God* would do something," while all the time ignoring the God who says, "I wish *you* would do something."

សំណាំងនិតឃ្នុំ ៤/១ (មករា ២០០៣)ៈ ៦០-៧៤



# ការថ្លឹងថ្លែងសេចក្តីអធិស្ឋាន ជាមួយការប្រព្រឹត្តិ

*រ៉ាស់ស៊ែល បាទរខ៊ីស៍*

ពេលខ្លះគ្រីស្ទាននិយាយថា “ប្រសិនបើយើងអាចអធិស្ឋានមែន ព្រះមុខជាអាចផ្លាស់ប្តូរពិភពលោកយើង ។ ការប្រជុំអធិស្ឋានគឺជាការប្រជុំសំខាន់បំផុតនៅក្នុងសប្តាហ៍ - ‘ម៉ោងនៃឫទ្ធានុភាព’ ។ សាតាំងមិនខ្វល់នូវអ្វីដែលយើងធ្វើទេ បើយើងមិនអធិស្ឋាន” ។ ការទាំងអស់នេះសបញ្ជាក់ឲ្យឃើញថា ការដែលនិយាយទៅរកព្រះសំខាន់ជាងការដែលព្រះមានបន្ទូលមករកយើង នៅពេលដែលយើងសិក្សាព្រះបន្ទូលទ្រង់ ។ វាបង្វិលការខ្លះដែលទ្រង់ចង់ឲ្យយើងធ្វើទៅទំលាក់លើព្រះអង្គវិញ ។ ហើយនាំយើងទៅរកការរំភើបនៃការអធិស្ឋាន និងពិធីតម សិក្ខាសាលា និងសន្និសីទនានា ។

ការអធិស្ឋានដែលពិតប្រាកដគឺជាសារៈសំខាន់ ។ ព្រះជួបជាមួយយើងនៅពេលដែលយើងអំពាវនាវរកព្រះអង្គ ។ ព្រះវិញ្ញាណរបស់ទ្រង់ជួយក្នុងការអធិស្ឋានរបស់យើង ផ្តាច់រនាំងបាបរបស់យើង បំបាក់អំនួត និងនាំយើងទៅរកព្រះគ្រីស្ទ ។ ព្រះឆ្លើយតបការអធិស្ឋាន និង “អាចធ្វើ

បានលើសជាងអ្វីដែលយើងសូម ហើយគិតទៅទៀត" ។ ប៉ុន្តែអ្នកខ្លះចង់ឈប់ត្រឹមកន្លែងនេះដោយគិតថា ការអធិស្ឋានគឺជាការគ្រប់គ្រាន់ហើយចំពោះការទទួលខុសត្រូវរបស់យើង - ហាក់បីដូចជាយើងគ្រាន់តែអធិស្ឋាន ហើយរង់ចាំ ។ គិតអីចឹងខុសហើយ! ទោះបីជាការអធិស្ឋាន គឺជាកូនសោឆ្ពោះទៅរកព្រះពររបស់ព្រះក៏ដោយ វាមិនមែនជាកូនសោតែមួយគត់នោះទេ ។ កូនសោមួយទៀតនោះ គឺការស្តាប់បង្គាប់ ។

អ្នកខ្លះមើលរំលងអំពីការនេះ ។ ការស្តាប់បង្គាប់ហាក់បីដូចជាឥតខ្លឹមសារបន្ទាប់ពីការអធិស្ឋាន ។ តើការស្តាប់បង្គាប់មិនមែនជាការប្រព្រឹត្តិរបស់មនុស្សដែរទេឬអី? តើមិនមែនជាការប្រព្រឹត្តិរបស់យើងទេឬដែលធ្វើឲ្យទាស់ចិត្តចេញពីភាពអស្ចារ្យលើសពីធម្មជាតិនៃការធ្វើឲ្យរស់ឡើងវិញខាងវិញ្ញាណ? តើសិរីល្អរបស់ព្រះមិនក្លាយទៅជាភាពស្រអាប់ទេឬប្រសិនបើការប្រព្រឹត្តិរបស់មនុស្សមានចំណែកនៅក្នុងនោះ? តើយើងកំពុងនិយាយអំពីរឿងនិមិត្តហេតុទីនេះឬ?

ដូច្នេះ តើយើងមានកំហឹងរួមជាមួយណាម៉ាន់ដោយនិយាយថា "មើលអញស្មានថាប្រាកដជាលោកនឹងចេញមកឯអញ ឈរអំពាវនាវដល់ព្រះនាមព្រះយេហូវ៉ាជាព្រះនៃលោក ហើយរាដៃពីលើដំបៅឲ្យរោគឃ្លង់បានជា..." ។ ណាម៉ាន់ហៀបតែនឹងធ្វើឲ្យបាត់បង់ការជាពីរោគរបស់គាត់ ដោយព្រោះគាត់រង់ចាំមើលព្រះធ្វើការ ជាជាងគាត់ចូលរួមដោយលោតចូលទៅក្នុងទន្លេយ័រដាន់ ។ តើយើងចង់នៅស្ងៀមចាំទទួលផលស្រាប់ (ចំណែករបស់យើង) និងទស្សនីយភាពដ៏អស្ចារ្យ (ចំណែករបស់ព្រះ) ។

ប៉ុន្តែទោះបីយ៉ាងណាក៏ដោយ មានពេលខ្លះពេលដែលរាស្ត្ររបស់ព្រះនៅរង់ចាំដោយមិនបាច់ធ្វើអ្វីទាំងអស់ (ដូចព្រះបាទ យេហូសាផាត) មានកន្លែងខ្លះទៀតពេលដែលព្រះមានបន្ទូលថា "ឈប់អធិស្ឋាន

ហើយចាប់ផ្តើមធ្វើការ" ។ នេះគឺជាព្រះបន្ទូលដែលយើងត្រូវការនៅថ្ងៃនេះ ។

## ពេលដែលយើងត្រូវឈប់អធិស្ឋាន ហើយចាប់ផ្តើមធ្វើសកម្មភាពវិញ

យ៉ូស្វេបានដឹកនាំអ៊ីស្រាអែលចូលទឹកដីសន្យា ។ ពួកគេបានយកជ័យជំនះលើទីក្រុងយេរេខូ ប៉ុន្តែបរាជ័យនៅទីក្រុងអៃ ។ ពួកអ៊ីស្រាអែលមានការភ័យញ័រ អ្នកដឹកនាំមានអារម្មណ៍អស់សង្ឃឹម ហើយពួកគេបានអធិស្ឋាន ។ គ្មានអ្វីដែលខុសទេចំពោះការនេះ ប៉ុន្តែតើអ្វីដែលព្រះទ្រង់មានបន្ទូល? សរុបឲ្យខ្លីព្រះមានបន្ទូលថា "ឈប់អធិស្ឋាន ។ បញ្ចេញសកម្មភាពវិញ ។ ឯងបានមិនស្តាប់បង្គាប់ ។ កែប្រែបញ្ហា" ។ តើយ៉ូស្វេនៅតែទាមទារអធិស្ឋានទៀតដែរទេឬអី នៅពេលដែលព្រះមានបន្ទូលឲ្យធ្វើ បើគេនៅតែធ្វើយ៉ាងដូច្នេះនោះគេនឹងមានការបរាជ័យជាថ្មីម្តងទៀត ។ តើយើងអាចដាក់ជំនួសការទូលអង្វរសំរាប់ជនជាតិ ឬពួកជំនុំរបស់យើងដោយអនុវត្តការងារសំខាន់ជាក់ស្តែងបាន ឬទេ?

យូដានៅក្នុងសម័យអេសាយអំពាវនាវសូមឲ្យមានការធ្វើឲ្យរីកផុសផុលខាងវិញ្ញាណ ។ ជនជាតិទាំងអស់អធិស្ឋានសំរាប់ការនេះ ប៉ុន្តែគ្មានការអ្វីកើតឡើងឡើយ ។ ពួកគេឆ្ងល់ថា ហេតុអ្វីបានជាយ៉ាងនេះ ។

.......រាល់តែថ្ងៃគេស្វែងរកអញជានិច្ច ហើយពេញចិត្តចង់ស្គាល់ផ្លូវរបស់អញ ទុកដូចជាសាសន៍ណាមួយដែលប្រព្រឹត្តដោយសុចរិត ឥតបោះបង់ចោលសេចក្តីយុត្តិធម៌របស់ព្រះនៃគេឡើយ គេសូមសេចក្តីវិនិច្ឆ័យដ៏សុចរិតពីអញ គេរីករាយចិត្តដោយចូលទៅជិតព្រះ គេពោលថា យើងតមអត់ ហេតុអ្វីបានជាទ្រង់មិនឃើញសោះ យើងខ្ញុំបានបញ្ឈឺចិត្តខ្លួន ហេតុអ្វីបានជាទ្រង់មិនយកចិត្តទុកដាក់ដូច្នេះ?

ពួកគេអធិស្ឋាន ប៉ុន្តែគ្មានការធ្វើឲ្យរស់ឡើងវិញខាងឯវិញ្ញាណកើតមានឡើងឡើយ ។ ពេលដែលពួកគេសួរថា ហេតុអ្វីបានជាព្រះមានបន្ទូលទៅអេសាយឲ្យពួកគេប្រកាសបដិសេធអំពើបាបរបស់គេ ។ ប្រសិនបើគេងើបឡើងពីការអធិស្ឋាន ហើយស្តាប់បង្គាប់នៅរាល់ទំនាក់ទំនង និងការទទួលខុសត្រូវប្រចាំថ្ងៃរបស់ពួកគេ នោះព្រះនឹងឆ្លើយតប ។ ពួកគេត្រូវតែកាច់បំបាក់នូវច្រវាក់នៃភាពអយុត្តិធម៌ ចែកចាយអាហារដល់អ្នកឃ្លាន ងាកចេញពីសំដីព្យាបាទគេ ។ល។ ទាំងនេះហាក់មិនសូវដូចជា "ភាពខាងឯវិញ្ញាណ" ដូចជាពិធីអធិស្ឋាន និងការតមនោះទេ ។ គឺមានការធ្វើជាមួយសកម្មភាពរបស់មនុស្ស និងទំនាក់ទំនងរបស់មនុស្ស មិនមែនជាការបង្ហាញទស្សនិយភាពដ៏អស្ចារ្យរបស់ព្រះនោះទេ ។ ប៉ុន្តែទាំងអស់នេះមិនមែនការអធិស្ឋានឡើយដែលជាកូនសោដើម្បីបើកឲ្យមានការធ្វើឲ្យរស់ឡើងវិញខាងឯវិញ្ញាណៈ យ៉ាងនោះទើបពន្លឺរបស់ឯងនឹងលេចមកដូចជារស្មីអរុណ ហើយសេចក្តីសុខស្រួលរបស់ឯង នឹងលេចឡើងជាយ៉ាងឆាប់...ឯងនិងបានដូចជាសួនច្បារដែលគេស្រោចទឹក ហើយដូចជាក្បាលទឹកដែលមិនខានហូរឡើយ ។ ព្រះពរសំរាប់យូដាគឺកើតឡើងតាមការស្តាប់បង្គាប់ មិនមែនការអធិស្ឋាន និងតមអាហារថែមទៀតនោះទេ ។

យើងបដិសេធយោបល់បែបនេះទាំងប្រថុយប្រថាន ។ "ចូរស្តាប់ព្រះបន្ទូលនៃព្រះយេហូវ៉ាចុះ ឱ អស់អ្នកក្នុងពួកយូដា ដែលចូលទៅថ្វាយបង្គំព្រះយេហូវ៉ាតាមទ្វារទាំងនេះអើយ ព្រះយេហូវ៉ានៃពួកពលបរិវារជាព្រះនៃសាសន៍អ៊ីស្រាអែលទ្រង់មានបន្ទូលដូច្នេះថា ចូរកែផ្លូវប្រព្រឹត្តនិងចរិតរបស់ឯងរាល់គ្នាឲ្យល្អវិញចុះ នោះអញនឹងឲ្យឯងរាល់គ្នាអាស្រ័យនៅទីនេះតទៅ" ។ (សូមកត់សំគាល់កន្លែងនេះ ព្រះមិនបានមានបន្ទូលយ៉ាងដូច្នេះទេថា "ចាប់ផ្តើមធ្វើពិធីអធិស្ឋាន២៤ម៉ោង" ឬ "បន្តតមឲ្យកាន់តែ

យូរថ្ងៃថែមទៀត" នោះទេ ។ ទ្រង់ក៏មិនបានបន្ទូល យ៉ាងដូច្នេះដែរថា "ចាប់ផ្ដើមអធិស្ឋានមកឯអញ" ប៉ុន្តែទ្រង់បែរជាមានបន្ទូលថា "ចាប់ផ្ដើមប្រព្រឹត្តសុចរិតនៅចំពោះមនុស្ស" វិញ) ។ "កុំឲ្យទុកចិត្តនឹងពាក្យកំភូតឡើយ ដោយនិយាយថា "នេះជាព្រះវិហារនៃព្រះ យេហូវ៉ា ជាព្រះវិហារនៃព្រះយេហូវ៉ា ជាព្រះវិហារនៃព្រះយេហូវ៉ា" ។ ដ្បិតបើអ្នករាល់គ្នាកែផ្លូវប្រព្រឹត្ត និងចរិតឯងឲ្យល្អ ហើយបើសំរេចក្ដីដល់មនុស្ស និងជិតខាងដោយយុត្តិធម៌...នោះអញនឹងឲ្យឯង អាស្រ័យនៅទីនេះតទៅ...។ មើលឯងរាល់គ្នាទុកចិត្តនឹងពាក្យកំភូត ដែលនឹងមានប្រយោជន៍មិនបាន" ។ ពាក្យកំភូតទាំងអស់នេះ បាននិយាយថា យូដាមិនត្រូវការស្ដាប់បង្គាប់ទេ ប៉ុន្តែពួកគេនៅតែបន្ត "ថ្វាយបង្គំ" ។ គួរឲ្យសោកស្ដាយ យូដាបានបដិសេធយេរេមា ហើយព្រះបានបញ្ជូននេប៊ូក្នេសាមកបញ្ចប់ការជួបជុំអធិស្ឋានដ៏រាក់កំផែលនៅក្នុងព្រះវិហារ ។

## ព្យាយាមប្រគល់ត្រឡប់ទៅវិញដល់ព្រះនូវកិច្ចការដែលទ្រង់បានប្រគល់ឲ្យយើង

តើការដូចគ្នានេះកើតឡើងសព្វថ្ងៃនេះដែរទេឬអី? តើយើងនៅតែអធិស្ឋាននៅពេលដែលព្រះប្រាប់យើងឲ្យបញ្ចេញសកម្មភាព? តើមានពួកជំនុំណាដែលធ្លាប់ព្យាយាមប្រគល់ទៅព្រះវិញនូវការទទួលខុសត្រូវដែលទ្រង់បានប្រគល់ឲ្យយើងធ្វើ? នេះគឺជាការដែលខ្ញុំគិតថាជា "ការផ្ទេរសិទ្ធិអំណាចទៅខាងលើ" ដ៏ពិតប្រាកដ ។

ឧទាហរណ៍ ព្រះបញ្ជាឲ្យយើងផ្សាយដំណឹងល្អ ។ យើងបង្វិលព្រះរាជបញ្ជារបស់ព្រះអង្គដោយគ្រាន់តែអធិស្ឋានសូមឲ្យព្រះអង្គធ្វើការនោះ - សូមព្រះអង្គ "បើកចិត្ត" អ្នកជិតខាងរបស់យើង ដោយយើងមិនបាច់និយាយអ្វីទាំងអស់ដល់ពួកគេ ។ ប្រហែលជាយើងតម្លើងផ្លាក

ព្រះវិហារឲ្យត្រង់ឡើងលើដើម្បីផ្តល់ដំណឹងដល់មនុស្សមានបាបដែលដើរកាត់នៅពេលដែលយើងជួប ប៉ុន្តែយើងបរាជ័យមិនបានណែនាំពួកគេឲ្យស្គាល់ព្រះគ្រីស្ទ ។ មិនមានអ្វីខុសក្នុងការដែលអង្វរសូមជំនួយមកអំពីព្រះអង្គក្នុងការផ្សាយដំណឹងល្អរបស់យើងនោះទេ ឲ្យតែយើងមានគំរោងការដើម្បីចូលរួមនៅក្នុងដំណើរការនោះដែរ ។ ឬយើង "បំពេញ" ការទទួលខុសត្រូវរបស់យើងដល់អ្នកឈឺ និងចាស់ជរាដោយអធិស្ឋានសូមឲ្យព្រះទ្រង់កំសាន្តចិត្តពួកគេ ប៉ុន្តែខ្លួនយើងវិញមិនទាំងដែលសួរសុខទុក្ខ និងផ្តល់អាហារដល់ពួកគេផងនោះ ។ យើងអធិស្ឋានដើម្បីសូមឲ្យព្រះអង្គកែតំរង់អំពីបញ្ហាសីលធម៌របស់ជនជាតិយើង ប៉ុន្តែមិនបានសរសេរសំបុត្រតវ៉ា និងថែមទាំងមើលរឿងវីដេអូដូចដែលពួកគេគ្រប់គ្នាមើលដែរ ។ យើងត្រូវបានបញ្ជូនឲ្យទៅឈោងចាប់ពិភពលោកតាមរយៈដំណឹងល្អ តែមានពួកជំនុំមួយចំនួនបែរជាគិតតែពីខ្លួនឯង ។ ព្រះជំរុញយើងឲ្យផ្តល់តម្លៃដល់គ្រួសារ និងប្រជាជនរបស់យើង និងដេញចាប់ការទាំងអស់នោះ ប៉ុន្តែយើងបែរជាអធិស្ឋានសំរាប់ការរីកផុសផុលទៅវិញ ។ តើមានអ្វីខុសចំពោះរូបភាពនេះ?

## ហេតុអ្វីបានជាមនុស្សមួយចំនួនចូលចិត្តអធិស្ឋានច្រើនជាង

ហេតុអ្វីបានជាយើងចូលចិត្តអធិស្ឋានច្រើនជាងការបញ្ចេញសកម្មភាព? ហេតុផលទីមួយប្រហែលជាភាពខ្ជិល ។ វាប្រហែលជាមានការងាយស្រួលជាងក្នុងការដែលគ្រាន់តែបើកមាត់របស់យើងអធិស្ឋានក្នុងខ្យល់ ជាជាងចំណាយជីវិតរបស់យើងទៅក្នុងតម្លៃនៃការស្តាប់បង្គាប់ ។ តាមពិតទៅការសង់ផ្ទះសំរាប់អ្នកក្រ គឺបែកញើសជាងគ្រាន់តែអធិស្ឋានសូមឲ្យព្រះប្រទានផ្ទះដល់អ្នកដែលត្រូវការ ។ ការដែលស្វែងរកយ៉ាងណាដែលជាការប្រសើរដើម្បីបំរើដល់អ្នកជិតខាងរបស់យើងហើយ

ធ្វើការសំរាប់ពួកគេដើម្បីបើកផ្លូវពួកគេនាំទៅរកជំហើងល្អ ធ្វើឲ្យយើងមានការហត់នឿយខ្លាំងជាង បើគ្រាន់តែសូមឲ្យព្រះមានបន្ទូលទៅរកពួកគេ ហើយបន្ទាប់មកទុកវាចោលដោយមិនបាច់ធ្វើអ្វីសោះ ។ ការងារមានការច្របូកច្របល់ដែរ ។ នៅពេលដែលយើងខំប្រឹងប្រែងដោះស្រាយជាមួយមនុស្សយើងបង្កើតកំហុស ។ យើងធ្វើការខ្វះខុស បង្កើតកំហុសដោយច្រកងងឹត បាត់បង់ភាពអត់ធ្មត់ ហើយលះបង់ចោល ។ យើងយល់ឃើញថា ខ្លួនយើងត្រូវការនិយាយសូមទោស ហើយចាប់ផ្តើមការងារម្តងទៀត ។ យើងជួបការរិះគន់ និងការចំអកឡកឡឺយ ។ តើអាចបន្ថយការភ័យស្លុត និងឆាប់មានកំហុសយ៉ាងណាបាន បើសិនជាយើងគ្រាន់តែលើកដាក់សម្លេងរបស់យើងតែក្នុងសេចក្តីអធិស្ឋានសំរាប់អាគារព្រះវិហាររបស់យើងនោះ ។ យើងចង់តែអធិស្ឋានជាងការស្តាប់បង្គាប់ដោយព្រោះតែការស្តាប់បង្គាប់ជាកិច្ចការលំបាកធ្ងន់ធ្ងរ ។

ការដាស់តឿន - ការអធិស្ឋានល្អគឺក៏ជាកម្លាំងខ្លាំងក្លាដែរ ។ អេប៉ាប្រាសបានមានបញ្ហានៅក្នុងការអធិស្ឋាន ហើយដូចគ្នាដែរក៏ធ្វើការយ៉ាងខ្លាំងក្លាសំរាប់ពួកជំនុំអាស៊ី ។ ប៉ុន្តែក្នុងខណៈដែលអេប៉ាប្រាស បានធ្វើការយ៉ាងធ្ងន់ធ្ងរជាមួយការអធិស្ឋាន គាត់ចាប់ផ្តើមមានសុខ្លួតែមនុស្សធ្វើការយ៉ាងសកម្មនៅឯការងាររបស់គាត់ ។ ពួកជំនុំដំបូងមិនបានត្រូវបោកបញ្ឆោតនៅក្នុងគំនិតគិតតែពីអធិស្ឋានតែមួយដែលជាចម្លើយនោះទេ ។

ហេតុផលទីពីរ យើងចូលចិត្តអធិស្ឋានជាងការបញ្ចេញសកម្មភាព គឺជាភាពអាត្មានិយម ។ ភាពអាត្មានិយមមានន័យថា ការខំប្រឹងប្រែងសំរាប់ការចាប់អារម្មណ៍ខ្លួនឯង ។ គ្រីស្ទបរិស័ទ ពួកជំនុំ មនុស្សហើយចុងក្រោយនោះ គឺព្រះជាម្ចាស់គ្រប់របស់ទាំងអស់មានឡើងដើម្បីបំពេញ និងសំរាប់តែធ្វើឲ្យខ្លួនយើងមានភាពស្រណុកស្រួលតែ

ប៉ុណ្ណោះ ។ ហើយនៅក្នុងខណៈពេលដែលត្រូវចែកទានដល់អ្នកក្រីក្រ ខ្ញុំស្ម័គ្រចិត្តអធិស្ឋានដើម្បីឲ្យព្រះប្រទានពរដល់អ្នកដទៃ ខ្ញុំមិនអាចមានហេតុផលណាដែលសង្ឃឹមថានឹងលះបង់ខ្លួនខ្ញុំដើម្បីនាំព្រះពរចេញទៅក្រៅនោះទេ ។ ការអធិស្ឋាន គឺថោកជាង ចំណែកឯការស្ដាប់បង្គាប់ត្រូវបង់តម្លៃយ៉ាងច្រើន ។

ទីបីប្រហែលភាពស្ទាក់ស្ទើរមិនពេញលក្ខណៈរបស់អំពើបាបបង្អាក់យើងមិនឲ្យស្ដាប់បង្គាប់ភ្លាមៗបាន ។ យើងកាត់បន្ថយអំពើបាបឲ្យទៅជាទស្សនៈបែបទេវវិទ្យាទៅវិញ - មូលហេតុដែលព្រះគ្រីស្ទយាងមក - ហើយលើកខគម្ពីរបញ្ជាក់ពីលក្ខណៈ និងផលវិបាកនៃទស្សនៈនោះ ។ បាបគ្រាន់តែក្លាយទៅជាគំនិតអរូបីតែប៉ុណ្ណោះ មិនមែនជាការជ្រើសរើសដ៏រឹងមាំ និងទំលាប់អាក្រក់ទេ ។ ប៉ុន្តែចំពោះព្រះវិញ បាបមិនមែនជាកំណត់នៅក្នុងទូដាក់សៀវភៅទេវវិទ្យារបស់យើងទេ ។ វាជាក្លិនស្អុយហើយកកូរព្រះពិរោធ និងការជំនុំជំរះរបស់ទ្រង់ ។ ហើយតាមរយៈព្រះលោហិតព្រះគ្រីស្ទ ទ្រង់អត់ទោសបាបឲ្យ យើងត្រូវតែរៀនពីភាពស្ទាក់ស្ទើរ ខ្លាច និងរត់គេចទៅផ្លូវដទៃទៀត ។ ពួកជំនុំមិនត្រូវតំអក់នៅក្នុងអំពើទុច្ចរិតទេ ទោះបីជាការខុសដែលយើងធ្វើ ឬការត្រឹមត្រូវដែលយើងមិនធ្វើហើយសង្ឃឹមថា ព្រះនឹងប្រទានពរដោយព្រោះតែយើងបានសូមព្រះអង្គដែរ ។ ប្រសិនបើការរីកដុលផុស ជាការដែលយើងចង់ពិតប្រាកដហើយយើងនឹងសូមសំរាប់វា ។ ប៉ុន្តែយើងនឹងស្ថិតនៅក្នុងការកោតខ្លាច និងជំនឿផងដែរ ក្នុងការស្ដាប់បង្គាប់ព្រះដែលជាអ្នកដែលផ្ដល់មកឲ្យយើង ។

ហេតុផលទីបួនការដែលយើងចង់អធិស្ឋានជាងការបញ្ចេញសកម្មភាពគឺដោយព្រោះមនុស្សខ្លះមិនយល់ថា តើការដែលយើងប្រព្រឹត្តមានសារៈសំខាន់ប៉ុណ្ណា ។ ពួកគេគិតថា ប្រសិនបើមនុស្សមានចំណែក

នៅក្នុងព័ន្ធកិច្ច នោះមានការរំខានដល់សិរីល្អរបស់ព្រះនៅក្នុងផលដែលបង្កើតឡើង ។ ប៉ុន្តែនេះមិនមែនជាការពិតទេ ។ ជាជាង "ចេញឲ្យឆ្ងាយទៅទុកឲ្យព្រះជាអ្នកធ្វើ" យើងត្រូវតែរៀនដូចការនេះវិញ "ចូលមកក្នុងជួរហើយធ្វើអ្វីដែលព្រះកំពុងធ្វើ" ។ លោកប៉ុលមិនបានគិតថា ការនេះជាចំណែកព្រះ ឬចំណែកយើងឡើយ នៅពេលដែលគាត់និយាយថា ក្រុមរបស់គាត់គឺគាត់មានន័យថា "បងប្អូនរួមការងារក្នុងព្រះ" ។

## ព្រះប្រើមនុស្ស

ពិតប្រាកដហើយ ព្រះគ្មានព្រំដែនឡើយក្នុងការប្រើមនុស្សនៅពេលដែលទ្រង់សព្វព្រះហឫទ័យចង់ធ្វើកិច្ចការអ្វីមួយ ។ យើងមិនបានបំរើដូចជាអ្នកប្រឹក្សា ឬជាវិស្វករនៅពេលដែលទ្រង់បង្កើតពិភពលោកទេ ។ ទ្រង់មានអំណាចអស្ចារ្យ ទ្រង់មានសេរីភាពក្នុងការធ្វើការគ្រប់ពេល និងជ្រើសរើសនរណាម្នាក់យ៉ាងណាក៏បានដែរ ។ ប៉ុន្តែជាទូទៅ និងមានន័យបំផុត គឺព្រះប្រើមនុស្សដើម្បីសំរេចបំណងព្រះហឫទ័យរបស់ព្រះអង្គ ។

គ្រីស្ទបរិស័ទយល់ថា ព្រះគម្ពីរគឺជាព្រះបន្ទូលព្រះ ។ ព្រះគម្ពីរទាំងមូលនេះត្រូវបានព្រះបណ្តាលឲ្យតែងឡើង ។ ហើយក្នុងពេលដែលការនោះជាសេចក្តីពិត គឺគ្មានពាក្យមួយម៉ាត់ណាដែលមិនបានឆ្លងកាត់តាមរយៈគំនិត និងមនុស្សដូចគ្នាដែរ ។ លោក ប៉ុល (មិនមែនព្រះទេ) គឺជាម្នាក់ដែលខ្លួនគាត់ផ្ទាល់ស្ទើរតែសូមឲ្យព្រះដាក់បណ្តាសា និងកាត់គាត់ចេញពីព្រះអង្គ ។ លោកយូដាជាអ្នកដែលឆេះឆួលក្នុងការសរសេរអំពីសេចក្តីសង្គ្រោះ ប៉ុន្តែបានមានអារម្មណ៍បង្ខំឲ្យសរសេរពីរឿងផ្សេងទៅវិញ ។ លោកលូកាជាបុគ្គលម្នាក់ដែលបានគិតថាជាការល្អក្នុងការសរសេររឿងដំណឹងល្អ ហើយបន្ទាប់មកគាត់បានធ្វើការស្រាវជ្រាវ ហើយក៏សរសេរឡើង ។ ព្រះគម្ពីរគឺជាព្រះបន្ទូលព្រះមួយរយភាគរយ ប៉ុន្តែក្នុង

ពេលជាមួយគ្នាដែរជាពាក្យរបស់មនុស្សមួយរយភាគរយ ។ នៅពេលដែលព្រះយល់ថាមនុស្សគួរតែកត់ត្រាពីបំណងព្រះហឫទ័យរបស់ព្រះអង្គ គឺទ្រង់មិនបានទំលាក់វាចុះពីមេឃក្នុងភាពអស្ចារ្យនោះទេ ។ នៅពេលដែលមនុស្សជួបឧបស័គ្គ... ហើយគិត... ហើយសរសេរឡើង និងពេលខ្លះសរសេរម្តងទៀត ។ ទោះបីជាមនុស្សបានចម្លង លាក់ទុក នាំចេញទៅ និងបកប្រែវាយ៉ាងណាក៏ដោយ ជាច្រើនសតវត្សកន្លងមកនេះព្រះបានរក្សាព្រះបន្ទូលនេះនៅតែដដែល ។ ទោះបីជាព្រះអង្គមិនត្រូវការក៏ដោយ ប៉ុន្តែព្រះអង្គតែងតែសំរេចកិច្ចការតាមរយៈមនុស្ស ។

មនុស្សភាពក៏ដូចជាទេវភាពរបស់ព្រះយេស៊ូដែរ គឺមានសារៈសំខាន់ដូចគ្នាដល់ព្រះគ្រីស្តវិទ្យា (ការសិក្សាអំពីព្រះគ្រីស្ត) របស់អ្នកដឹកនាំដំណឹងល្អ ។ ព្រះយេស៊ូគឺជាមនុស្ស ។ យើងត្រូវតែចងចាំថា "នោះសេចក្តីដែលមនុស្សស្លាប់រស់ឡើងវិញ គឺមកតាមរយៈមនុស្សដែរ...មានព្រះតែមួយ ហើយអ្នកបង្រួបបង្រួមតែមួយនៅកណ្តាលព្រះនិងមនុស្ស គឺជាមនុស្សដ៏ជាគ្រីស្តយេស៊ូនោះ...ហេតុនោះបានជាគួរឲ្យទ្រង់ដូចបងប្អូនទ្រង់គ្រប់ជំពូកដែរ ដើម្បីឲ្យបានធ្វើជាសំដេចសង្ឃដែលមានសេចក្តីមេត្តាករុណា ហើយក៏ស្មោះត្រង់ក្នុងការទាំងប៉ុន្មានខាងឯព្រះប្រយោជន៍នឹង ថ្វាយដង្វាយឲ្យធួននិងបាបរបស់ប្រជាជនទាំងឡាយ..." ។ សេចក្តីសង្គ្រោះរបស់ព្រះមិនមែនទៅជាខ្សោយកម្លាំងក្នុងការប្រើព្រះយេស៊ូជាអ្នកភូមិណាសារ៉ែតដើម្បីសំរេចកិច្ចការនោះទេ ។ តែផ្ទុយទៅវិញការសង្គ្រោះនឹងមិនអាចកើតឡើងបានបើសិនជា បុរសយេស៊ូមិនបានរួមចំណែក ។ ដូចគ្នានឹងព្រះបន្ទូលជាលាយលក្ខណ៍អក្សរដែរ ព្រះបន្ទូលដែលចាប់កំណើតជាមនុស្ស ក៏ជាព្រះមួយរយភាគរយ និងជាមនុស្សមួយរយភាគរយ ។ ក្នុងនាមជាមនុស្ស ព្រះគ្រីស្តអាចមានបន្ទូលបានថា "ត្បិតខ្ញុំបានធ្វើដំរាប់ទុកឲ្យអ្នករាល់គ្នា ហើយដើម្បីឲ្យ

អ្នករាល់គ្នាត្រាប់តាមការដែលខ្ញុំបានធ្វើឲ្យនោះ" ។ សេចក្តីសង្គ្រោះដ៏អស់កល្ប គឺជាកិច្ចការរបស់ព្រះ ។ ប៉ុន្តែដោយព្រោះព្រះយេស៊ូ គឺជាព្រះអង្គសង្គ្រោះ វាក៏ជាកិច្ចការរបស់មនុស្សដែរ – ម្នាក់ដែលដូចយើងក្នុងគ្រប់ផ្លូវទាំងអស់ ។ សិរីល្អរបស់ព្រះនឹងមិនមានការថយចុះទេនៅពេលដែលទ្រង់ប្រើមនុស្ស – ហើយការស្តាប់បង្គាប់របស់ពួកគេ និងការលះបង់របស់ពួកគេ – ដើម្បីបំពេញគំរោងផែនការរបស់ព្រះអង្គ ។

## តើអ្នកណាសាងសង់ពួកជំនុំ?

តើពួកជំនុំសព្វថ្ងៃមានការរីកចំរើនយ៉ាងណា? ព្រះយេស៊ូវមានព្រះបន្ទូលថា "ខ្ញុំនឹងសាងសង់ពួកជំនុំខ្ញុំឡើង" ។ ព្រះគម្ពីរកិច្ចការបានចាប់ផ្តើមថា "ឱលោកថេភីលអើយ ខ្ញុំបានតែងរឿងមួយច្បាប់មុននោះពីអស់ទាំងការដែលព្រះយេស៊ូវបានចាប់តាំងធ្វើហើយបង្រៀន..." ។ ការអនុវត្តន៍គឺថាកណ្ឌកិច្ចការបានសរសេរចុះពីអ្វីដែលព្រះយេស៊ូវបន្តធ្វើ និងបង្រៀន ។ ប៉ុន្តែ តើទ្រង់សាងសង់ពួកជំនុំរបស់ព្រះអង្គយ៉ាងដូចម្តេច? តើទ្រង់បន្តធ្វើ និងបន្តបង្រៀនយ៉ាងដូចម្តេច? ។ តាមរយៈមនុស្ស ។ កណ្ឌកិច្ចការបានសរសេរចុះនូវការធ្វើដំណើរតាមទូក...បញ្ហា...សេចក្តីអធិប្បាយ...និងការវេទនាខ្លះៗ ។ លោកប៉ុលបានប្រាប់ដល់ពួកជំនុំនៅកូលុស "ហើយសេចក្តីវេទនាណារបស់ព្រះគ្រីស្ទដែលខ្វះក្នុងរូបសាច់ខ្ញុំ នោះខ្ញុំកំពុងតែបំពេញឡើងដោយព្រោះរូបកាយទ្រង់ គឺជាពួកជំនុំ..." ។ កណ្ឌកិច្ចការនិយាយថា ព្រះគ្រីស្ទ គឺជាអ្នកដែលសាងសង់ពួកជំនុំកូលុស ។ តើការទាំងពីរនេះ អាចស៊ីគ្នាយ៉ាងដូចម្តេចបាន? ព្រះគ្រីស្ទសាងសង់ពួកជំនុំតាមរយៈលោកប៉ុល ។ ព្រះធ្វើកិច្ចការរបស់ព្រះអង្គតាមរយៈមនុស្ស ។ ហើយព្រះគ្រីស្ទសាងសង់ពួកជំនុំរបស់ព្រះអង្គសព្វថ្ងៃនេះតាមការដែលមនុស្សស្តាប់បង្គាប់ព្រះអង្គ – មិនត្រូវ

ជ្រើសរើសខុសពីផ្លូវរបស់ព្រះទេ ប៉ុន្តែចូលក្នុងជួររបស់ព្រះអង្គ ហើយធ្វើអ្វីតាមដែលទ្រង់កំពុងធ្វើ ។ គ្មានពួកជំនុំណាសាងសង់ឡើងបានដោយគ្មានការផ្សាយដំណឹងល្អ បង្រៀន ការថ្វាយ បំរើ និងកម្លាំងមនុស្សនោះទេ...ដូចដែលគេត្រូវបានជំរុញ និងផ្ដល់អំណាចដោយព្រះវិញ្ញាណរបស់ព្រះ ។ ពួកជំនុំរីកចំរើន និងសង់ខ្លួនវាឡើងនៅក្នុងសេចក្ដីស្រឡាញ់ដូចដែលផ្នែកនីមួយៗធ្វើការរបស់វា មិនមែនផ្នែកមួយអង្គុយ ហើយរង់ចាំព្រះឲ្យធ្វើការរបស់ព្រះអង្គ ។ ប៉ុន្តែវាជាកិច្ចក្នុងពេលជាមួយគ្នារវាងព្រះហើយនឹងមនុស្ស ។

ដូចគ្នាដែរជាមួយការរីកផុលផុស ។ ពិតហើយ យើងត្រូវតែអធិស្ឋាន ។ ប៉ុន្តែយើងក៏ត្រូវតែធ្វើផងដែរ ។ ការងាររបស់យើងមិនមែនធ្វើឲ្យអន់ថយចេញពីការងាររបស់ព្រះទេ ឬបន្ថយសិរីល្អរបស់ទ្រង់នៅពេលដែលចម្លើយធ្លាក់មកនោះទេ ។ ព្រះតែងតែធ្វើកិច្ចការរបស់ព្រះអង្គតាមរយៈមនុស្ស ។ ដូច្នេះយើងត្រូវតែបន្តអំពាវនាវដល់ពួកជំនុំ ឲ្យលះបង់កន្លែងស្ងាត់ស្ងៀមរបស់ពួកគេ ឲ្យមកស្ដាប់បង្គាប់ និងចូលរួមនៅក្នុងទីផ្សារវិញ ។ នៅពេលដែលយើងកំពុងរវល់អនុវត្តសេចក្ដីសុចរិតប្រចាំថ្ងៃ។

យ៉ាងនោះ ទើបពន្លឺរបស់ឯងនឹងលេចមកដូចជារស្មី អរុណ ហើយសេចក្ដីសុខស្រួលរបស់ឯងនឹងលេចឡើងជា យ៉ាងឆាប់....ឯងនិងបានដូចជាសួនច្បារដែលគេស្រោចទឹក ហើយដូចជាក្បាលទឹកដែលមិនខានហូរឡើយ ។

បុណ្យថ្ងៃទី ៥០ នឹងមិនកើតឡើងទៀតទេ មិនត្រូវការអធិស្ឋានឲ្យការនោះកើតឡើងទៀតទេ ។ ពួកជំនុំឈររួចហើយ "រុំដោយអំណាចដែលមកពីខាងលើ" ។ យើងត្រូវការអ្នកត្រាស់ហៅថែមទៀត ដើម្បីទទួលនូវតួនាទីដែលយើងបានទទួលមក ហើយសំរេចនៅក្នុងកម្លាំងនៃព្រះដែលទ្រង់ប្រគល់មកឲ្យយើង ។

## តើព្រះជាម្ចាស់ ចង់បានអ្វី?

គ្រីស្តសាសនាគ្មានលក្ខណៈស្មុគស្មាញទេ ។ តើព្រះអង្គដ៏ខ្លាំងពូកែចង់បានពិធីលះបង់ខ្លួនរបស់យើងឬ? ព្យាការីមីកាត្រិះរិះពីសំណួរនេះ:

តើត្រូវឲ្យខ្ញុំយកអ្វីចូលទៅចំពោះព្រះយេហូវ៉ា ហើយក្រាបថ្វាយ
បង្គំនៅមុខព្រះដ៏ខ្ពស់?
តើត្រូវឲ្យខ្ញុំយកដង្វាយដុតជាកូនគោអាយុមួយខួប ដើម្បីចូលទៅ
ចំពោះទ្រង់ឬ?
តើព្រះយេហូវ៉ានឹងសព្វព្រះហឫទ័យដោយចៀមទាំងពាន់
ឬប្រេងទាំងម៉ឺនទន្លេឬអី?
តើត្រូវឲ្យខ្ញុំថ្វាយកូនច្បងខ្ញុំឲ្យបានធួននឹងអំពើរំលងដែលខ្ញុំប្រព្រឹត្ត
គឺជាផលនៃរូបកាយខ្ញុំ ឲ្យបានធួននឹងបាបនៃព្រលឹង
ខ្ញុំឬ?
ឱមនុស្សអើយ ព្រះបានបង្ហាញឲ្យឯងស្គាល់សេចក្តីដែលល្អ
តើព្រះយេហូវ៉ាសព្វព្រះហឫទ័យឲ្យឯងប្រព្រឹត្តដូច
ម្តេច?
បើមិនមែនឲ្យប្រព្រឹត្តដោយសុចរិត ឲ្យស្រឡាញ់សេចក្តី
សប្បុរស ហើយឲ្យដើរជាមួយព្រះនៃខ្លួនដោយសុភាព
រាបទាបប៉ុណ្ណោះ ។

សេចក្តីបញ្ចប់របស់មីកាគឺសាមញ្ញ ។ ព្រះមិនបានស្វែងរកការអធិស្ឋានដ៏វែងៗ ឬការតមដ៏យូររបស់យើងទេ ។ ទ្រង់មិនស្ទើចដល់អ្នកណាមួយ ដែលបង្ហាញខ្លួនគេឲ្យគេឃើញថាខ្លួនស្កាប់បង្កាប់រាល់ថ្ងៃនោះទេ ។ ស្រដៀងគ្នាដែរដើម្បីឆ្លើយតបទៅនឹងសំណួររបស់អ្នកនិពន្ធ

ទំនុកតំកើង "ព្រះយេហូវ៉ា ប្រហែលជាគង់នៅក្នុងរោងឧបោសថរបស់ឯង?" មិនបាននិយាយអំពីពិធីរបស់សាសនាទេ ប៉ុន្តែបែរជានិយាយអំពីការអនុវត្តន៍សេចក្តីសុចរិតប្រចាំថ្ងៃវិញ ។ នៅពេលដែលមនុស្សសួរលោកយ៉ូហាន បាប់ទីស្ទ "តើយើងគួរធ្វើដូចម្តេច?" គាត់បានឆ្លើយជារបៀបលោកីយ៍ថា "ត្រូវស្តាប់ចិត្តនូវអ្វីដែលអ្នកមានដោយចែកចាយទ្រព្យសម្បត្តិ ហើយប្រព្រឹត្តដោយស្មោះត្រង់" ។ គ្មានអ្វីដែលអស្ចារ្យ ឬ "សាសនា" អ្វីនៅទីនេះឡើយ ។ ប៉ុន្តែទ្រង់នឹងប្រទានពរប្រសិនបើគេស្តាប់បង្គាប់ ។

តើយើងតែងតែនិយាយជារឿយៗយ៉ាងណាថា "ខ្ញុំនឹងអធិស្ឋានឲ្យអ្នក" នៅពេលដែលយើងត្រូវនិយាយយ៉ាងដូច្នេះវិញ "សូមឲ្យខ្ញុំជួយអ្នក" ។ ការអធិស្ឋានមិនមែនជាសេចក្តីបញ្ចប់នៃការទទួលខុសត្រូវរបស់យើងនោះទេ ប៉ុន្តែ វាគ្រាន់តែជាការចាប់ផ្តើមៈ វាបើកទ្វារសំរាប់ព្រះក្នុងការតំរង់ និងផ្តល់កម្លាំងដល់យើងសំរាប់កិច្ចការងាររបស់យើង។ ទោះបីយ៉ាងណាក៏ដោយ ប្រហែលជាអាចភ្ជាប់ទៅលើទេវវិទ្យារបស់អ្នកម្តាយថេរេសា (Theresa) ដែលបានធ្វើច្រើនខាងឯការប្រព្រឹត្តិរបស់គាត់ ដើម្បីធ្វើឲ្យគ្រីស្តបរិស័ទ និងព្រះគ្រីស្ត មានការគោរពក្នុងចំណោមជនដែលមិនមែនគ្រីស្តបរិស័ទឥណ្ឌា ជាជាងការគិតរាប់ពាន់ពាក្យតាមព្រះគម្ពីរតែមិនធ្វើអ្វីសោះ ។ "កូនរាល់គ្នាអើយ! សូមកុំស្រឡាញ់" ឬស្វែងរកការរីកផុលផុស ឬព្យាយាមចាំមនុស្សបាត់បង់មករកព្រះ "ដោយប្រើតែពាក្យសំដីប៉ុណ្ណោះឡើយ ប៉ុន្តែសូមប្រើសកម្មភាព និងសេចក្តីពិតវិញ" ។

ដោយគ្មានការសង្ស័យឡើយ ប្រជាជាតិរបស់យើងត្រូវការព្រះហស្តរបស់ព្រះមកដាក់លើយើង ។ ពិតប្រាកដហើយយើងត្រូវការអធិស្ឋានសំរាប់ការនេះ ។ ប៉ុន្តែវិតតែពិតប្រាកដទៀតដែរថា យើងត្រូវតែធ្វើនូវអ្វីដែលព្រះទ្រង់បញ្ជា ។ យើងត្រូវតែក្រោកឡើងបន្ទាប់ពីលុតជង្គង់អធិស្ឋាន ឈានជើងចេញដំណើរ កំរើកប្រអប់ដៃជួយធ្វើការ

បើកមាត់និយាយ និងលាតដៃអោប ក្រសោបគ្នា ។ ការអធិស្ឋានគឺជាកូនសោឆ្ពោះទៅរកការរីកផុលផុស ប៉ុន្តែការស្តាប់បង្គាប់ក៏ដូចគ្នាដែរ ។ ព្រះទ្រង់ឆ្លើយតបទៅលើការអធិស្ឋាន ប៉ុន្តែទ្រង់តែងតែឆ្លើយតបតាមរយៈមនុស្ស ។ ប្រហែលជាការឆ្លើយតបរបស់ព្រះអង្គរួមបញ្ចូលយើងដែរ ។ ប្រហែលជាយើងមិនមានអារម្មណ៍ថា យើងមានកំហុសក្នុងការគ្រាន់តែអង្គុយ ហើយច្រៀងដោយ គិតថា “អញប្រាថ្នាថាព្រះគួរធ្វើការអ្វីមួយ” ក្នុងខណៈពេលដែលបដិសេធ គ្រប់ពេលទាំងអស់ចំពោះព្រះដែលមានព្រះបន្ទូលថា “អញប្រាថ្នាថាឯង គួរធ្វើការអ្វីមួយ” ។